EN
ID
MS
ZH
JA
KM
KO
LO
MY
TH
VI

# ជំពូកទី ១៖ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

ឆ្នាំ២០២៣ ជាឆ្នាំដែលសេដ្ឋកិច្ចសកល ក៏ដូចជាតំបន់អាស៊ាន+៣ ជួបប្រទះរឿងកើតឡើងពីរផ្សេងគ្នា។ សម្រាប់ពាក់កណ្ដាលឆ្នាំដំបូង យើងឃើញថាមានការបន្តរឹតត្បឹតខ្លាំងនៃនយោបាយរូបិយវត្ថុ និងអស្ថិរភាពទីផ្សារហិរញ្ញវត្ថុ រយៈពេលខ្លីនៅសហរដ្ឋអាមេរិក និងអឺរ៉ុប និងការកើនឡើងខ្លាំងនៃអតិផរណា។ សម្រាប់ពាក់កណ្ដាលឆ្នាំចុងក្រោយ ការរឹតបន្តឹងនយោបាយរូបិយវត្ថុត្រូវបានផ្អាក ទីផ្សារហិរញ្ញវត្ថុមានស្ថិរភាព ហើយកំណើនសេដ្ឋកិច្ចនៅអាមេរិក និងអឺរ៉ុបបង្ហាញពីភាពធន់ ស្របជាមួយការថយចុះអតិផរណា។

សេដ្ឋកិច្ចប្រទេសអាស៊ាន+៣ កើន ៤,៣ ភាគរយ ក្នុងឆ្នាំ២០២៣ ពោលគឺ ខ្ពស់ជាងឆ្នាំ២០២២ ដែលបានកើនក្នុងអត្រា ៣,២ ភាគរយ ដែលគាំទ្រដោយកំណើនរឹងមាំនៃតម្រូវការក្នុងស្រុក ទោះបីជាការនាំចេញមានភាពទន់ខ្សោយ។ អតិផរណាក្នុងតំបន់បានថយចុះមកកម្រិតមធ្យម ទោះបីជាអតិផរណា ស្នូលនៅតែមានកម្រិតខ្ពស់ ដោយសារភាពរឹងមាំនៃតម្រូវការក្នុងស្រុក។ ទន្ទឹមនេះ ស្ថានភាពហិរញ្ញវត្ថុមានភាពល្អប្រសើរឡើងរហូតដល់ចុងឆ្នាំ ជាមួយនឹងភាពរឹងមាំនៃកំណើនឥណទាន ការងើបឡើងវិញនៃទីផ្សារមូលធន ការថយចុះទិន្នផលសញ្ញាបណ្ណ និងស្ថិរភាពអត្រាប្តូរប្រាក់។ ទុនបម្រុងអន្តរជាតិបន្តមានកម្រិតសមស្រប និងបានចូលរួមចំណែករក្សាភាពធន់នៃវិស័យខាងក្រៅរបស់តំបន់។

សេដ្ឋកិច្ចប្រទេសអាស៊ាន+៣ ត្រូវបានរំពឹងថានឹងមានការកើនឡើងលឿនប្រមាណ ៤,៥ ភាគរយ ក្នុងឆ្នាំ២០២៤ នឹងថមថយមក ៤,២ ភាគរយ ក្នុងឆ្នាំ២០២៥។ តម្រូវការក្នុងស្រុក រំពឹងថានៅតែមានភាពធន់ គាំទ្រដោយការងើបឡើងវិញនៃការវិនិយោគ និងភាពរឹងមាំនៃការចំណាយរបស់អ្នកប្រើប្រាស់។ ការងើបឡើងវិញនៃការនាំចេញ ជាពិសេសក្នុងវិស័យផលិតកម្មគ្រឿងបង្គុំអេឡិចត្រូនិក និងការកើនឡើងខ្ពស់នៃវិស័យទេសចរណ៍ អាចជួយជំរុញបន្ថែមដល់កំណើនសេដ្ឋកិច្ច។ នៅក្នុងរយៈពេលមធ្យម តំបន់អាស៊ាន+៣ ត្រូវបានរំពឹងថានឹងបន្តក្នុងការជំរុញកំណើនសេដ្ឋកិច្ចសកល ពោលគឺ កើនឡើងលឿនជាងកំណើនមធ្យមរបស់សកល និងរួមចំណែកប្រមាណ ៤៥ ភាគរយ ទៅក្នុងកំណើនសេដ្ឋកិច្ចសកល ក្នុងឆ្នាំ២០២៤-២០៣០។ អតិផរណាត្រូវបានប៉ាន់ស្មានថានឹងបន្តថមថយ ប៉ុន្តែថមថយក្នុងលក្ខណៈសន្សឹមៗ ខណៈដែលអតិផរណាស្នូល រំពឹងថានឹងបន្តកើនឡើង ដោយសារភាពរឹងមាំនៃតម្រូវការក្នុងស្រុក។

ទស្សនវិស័យរយៈពេលខ្លីសម្រាប់ប្រទេសអាស៊ាន+៣ អាចនឹងទទួលរងឥទ្ធិពលពីហានិភ័យមួយចំនួនផងដែរ។ ការហក់ឡើងខ្លាំងនៃថ្លៃទំនិញសកលដោយសារការកើនឡើងនៃភាពតានតឹងភូមិសាស្ត្រនយោបាយ ឬហានិភ័យពីការប្រែប្រួលអាកាសធាតុដែលជាបញ្ហាប្រឈមចម្បង។ ហានិភ័យផ្សេងទៀត រួមមាន កំណើនយឺតជាងការរំពឹងទុករបស់សេដ្ឋកិច្ចប្រទេសចិន ផលប៉ះពាល់អវិជ្ជមានពីយុទ្ធនាការបោះឆ្នោតប្រធានាធិបតីរបស់សហរដ្ឋអាមេរិក និងការដែលអាចធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសអភិវឌ្ឍន៍ធំៗក្រៅតំបន់។ នៅក្នុងរយៈពេលវែង ការកើនឡើងការប្រឈមមុខគ្នាក្នុងភូមិសាស្ត្រនយោបាយ ការមិនបានត្រៀមខ្លួនគ្រប់គ្រាន់សម្រាប់ការកើនឡើងនៃប្រជាជនវ័យចំណាស់ ការប្រែប្រួលអាកាសធាតុ ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត និងការផ្ទុះឡើងវិញនៃជំងឺឆ្លងនានា នៅតែជាបញ្ហាប្រឈមដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។

យ៉ាងណាមិញ ទស្សនវិស័យវិជ្ជមានបច្ចុប្បន្នក្នុងតំបន់អាស៊ាន+៣ នឹងផ្តល់ឱកាសសម្រាប់ការស្តារឡើងវិញនូវលំហគោលនយោបាយដែលបានបាត់បង់ក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ-១៩។ ក្នុងឆ្នាំ២០២៣ គោលនយោបាយពង្រឹងប្រសិទ្ធភាពចំណាយ (Fiscal Consolidation) ត្រូវបានបន្តអនុវត្តនៅក្នុងប្រទេសជាច្រើនក្នុងតំបន់អាស៊ាន+៣ ទោះបីជាប្រទេសភាគច្រើនមិនទាន់អាចសម្រេចបានលំហគោលនយោបាយវិញបានទាំងស្រុងដូចមុនគ្រាវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ ខណៈដែលធនាគារកណ្តាលស្ទើរតែទាំងអស់នៅក្នុងតំបន់ បន្តរក្សានយោបាយរូបិយវត្ថុរឹតត្បឹតដើម្បីឆ្លើយតបទៅនឹងសម្ពាធអតិផរណា។ នាពេលអនាគត អាទិភាពសម្រាប់នយោបាយសារពើពន្ធ គួរតែត្រូវបានដាក់ចេញក្នុងគោលដៅស្តារមកវិញនូវទ្រនាប់សារពើពន្ធ (Fiscal Buffer) ស្របជាមួយនឹងការដាក់ចេញនូវវិធានការគាំទ្រសេដ្ឋកិច្ចតាមគោលដៅអាទិភាព។ ទន្ទឹមនេះ តួនាទីសំខាន់របស់នយោបាយរូបិយវត្ថុ គឺផ្តោតលើការរក្សាឱ្យបាននូវការរំពឹងទុកអតិផរណា (Inflation Expectation) ដោយសារហានិភ័យនៃការបន្តការកើនឡើងនៃអតិផរណា។

ងាកទៅរកការវិវត្តចាប់តាំងពីការផ្ទុះឡើងនៃវិបត្តិជំងឺកូវីដ-១៩ ទោះបីជាក្នុងគ្រាដំបូងមានការងើបឡើងវិញខ្លាំងក៏ដោយកំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ក្នុងតំបន់ នៅតែមាននិន្នាការទាបជាងគ្រាមុនពេលមានវិបត្តិជំងឺកូវីដ-១៩។ ការណ៍នេះ បានឆ្លុះបញ្ចាំងពីការកែសម្រួល និងស្លាកស្នាមនៃផលប៉ះពាល់នានា ដែលបានបន្ទាបមូលដ្ឋាននៃកំណើន គួបផ្សំនឹងបញ្ហាប្រឈមផ្សេងៗក្នុងស្ថានភាពសេដ្ឋកិច្ចសកល។ ទន្ទឹមនេះ ការងើបឡើងវិញនៃការវិនិយោគ បន្តមានភាពទន់ខ្សោយ។ គោលនយោបាយគាំទ្រការវិនិយោគទាំងផលិតភាព និងភាពធន់ ជាពិសេសសម្រាប់សហគ្រាសធុនតូច គឺមានសារៈសំខាន់ក្នុងការជំរុញកំណើនឱ្យទៅរកនិន្នាការដូចគ្រាមុនវិបត្តិជំងឺកូវីដ-១៩។ ទំនាក់ទំនងជិតស្និទ្ធនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ ក៏អាចជួយជំរុញសក្តានុពលកំណើនដែលបានរងឥទ្ធិពលពីវិបត្តិជំងឺកូវីដ-១៩ ផងដែរ។

*សំណេរនេះជាការបកប្រែពីភាសាអង់គ្លេសដើមសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ក្នុងករណីមានភាពខុសគ្នា គួរយោងទៅសំណេរភាសាអង់គ្លេស។*

**អាស៊ាន+៣៖ ការប៉ាន់ស្មាន និងការព្យាករ របស់ AMRO សម្រាប់កំណើនសេដ្ឋកិច្ច និងអតិផរណា ឆ្នាំ២០២៤-២០២៥**
(គិតជាភាគរយ ឆ្នាំលើឆ្នាំ)

| សេដ្ឋកិច្ច | កំណើនសេដ្ឋកិច្ច | | | អតិផរណា | | |
|---|---|---|---|---|---|---|
| | ២០២៣ ប៉ាន់. | ២០២៤ ព្យា. | ២០២៥ ព្យា. | ២០២៣ ប៉ាន់. | ២០២៤ ព្យា. | ២០២៥ ព្យា. |
| អាស៊ាន+៣ | ៤,៣ | ៤,៥ | ៤,២ | ៦,៣ | ៤,៣ | ៣,៧ |
| មិនរាប់បញ្ចូលប្រទេសឡាវ និង មីយ៉ាន់ម៉ា | – | – | – | ២,៨ | ២,៥ | ២,៣ |
| ប្រទេស +៣ | ៤,៤ | ៤,៤ | ៤,១ | ២,៣ | ២,១ | ២,០ |
| ចិន | ៥,២ | ៥,៣ | ៤,៩ | ០,២ | ១,០ | ២,០ |
| ហុងកុង | ៣,២ | ៣,៥ | ៣,០ | ២,១ | ២,៥ | ២,៣ |
| ជប៉ុន | ១,៩ | ១,១ | ១,០ | ៣,៣ | ២,៥ | ២,១ |
| កូរ៉េ | ១,៤ | ២,៣ | ២,១ | ៣,៦ | ២,៥ | ២,០ |
| ប្រទេសអាស៊ាន | ៤,២ | ៤,៨ | ៤,៩ | ៨,០ | ៥,៣ | ៤,៤ |
| មិនរាប់បញ្ចូលប្រទេសឡាវ និង មីយ៉ាន់ម៉ា | – | – | – | ៣,០ | ២,៧ | ២,៤ |
| ប្រ៊ុយណេ | ១,៤ | ២,៧ | ២,៩ | ០,៤ | ១,៤ | ១,០ |
| កម្ពុជា | ៥,៣ | ៦,២ | ៦,៤ | ២,១ | ៣,១ | ២,៨ |
| ឥណ្ឌូនេស៊ី | ៥,០ | ៥,២ | ៥,២ | ៣,៧ | ២,៨ | ២,៥ |
| ឡាវ | ៤,៣ | ៤,៧ | ៤,៩ | ៣១,២ | ១៤,៣ | ៩,៣ |
| ម៉ាឡេស៊ី | ៣,៧ | ៥,០ | ៤,៧ | ២,៥ | ២,៥ | ៣,០ |
| មីយ៉ាន់ម៉ា | ៣,៤ | ៣,២ | ៣,២ | ២៤,៤ | ១៦,១ | ១៥,៨ |
| ហ្វីលីពីន | ៥,៦ | ៦,៣ | ៦,៥ | ៦,០ | ៣,៦ | ២,៩ |
| សិង្ហបុរី | ១,១ | ២,៦ | ១,៩ | ៤,៨ | ៣,០ | ២,៥ |
| ថៃ | ១,៩ | ២,៩ | ៣,១ | ១,២ | ១,២ | ១,៩ |
| វៀតណាម | ៥,១ | ៦,០ | ៦,៥ | ៣,៣ | ៣,៦ | ២,៧ |

ប្រភព៖ អាជ្ញាធរជាតិតាមរយៈ CEIC និង Haver Analytics; ការប៉ាន់ស្មាន និងការព្យាកររបស់ AMRO។
ចំណាំ៖ ប៉ាន់=ប៉ាន់ស្មាន; ព្យា=ព្យាករ; កំណើនសេដ្ឋកិច្ច និងអតិផរណារបស់មីយ៉ាន់ម៉ាគឺផ្អែកលើឆ្នាំសារពើពន្ធដែលចាប់ផ្តើមពីថ្ងៃទី ១ ខែមេសា ដល់ថ្ងៃទី ៣១ ខែមីនា។ ការគណនាកំណើនសរុបក្នុងតំបន់ ត្រូវបានប៉ាន់ស្មានដោយប្រើមធ្យមភាគទម្ងន់នៃ ផ.ស.ស ឆ្នាំ២០២២ តាមមូលដ្ឋានយុគភាពអំណាចទិញ; ការគណនាអតិផរណាសរុបក្នុងតំបន់ ត្រូវបានគណនាតាមការធ្វើមធ្យមភាគ។

# ជំពូកទី ២៖ តម្រង់ទិសសម្រាប់អនាគត

តំបន់អាស៊ាន+៣ បានសម្រេចបាននូវវឌ្ឍនភាពសេដ្ឋកិច្ចយ៉ាងខ្លាំងក្លាក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ ជារួម សេដ្ឋកិច្ចប្រទេសក្នុងតំបន់អាស៊ាន+៣ បានក្លាយជាកម្លាំងចលករដ៏ធំបំផុតនៃកំណើនសេដ្ឋកិច្ចសកល។ ទោះជាយ៉ាងណាក្ដី កត្តាអំណោយផលដែលបានជួយជំរុញកំណើនបាននិងកំពុងថមថយ ខណៈដែលហានិភ័យបានបន្តកើនឡើង ហើយល្បឿននៃកំណើនក្នុងតំបន់ក្នុងការតាមឱ្យទាន់នឹងកំណើនប្រទេសដែលមានប្រាក់ចំណូលខ្ពស់ផ្សេងទៀត បានថមថយចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨-២០០៩។ លើសពីនេះ សេដ្ឋកិច្ចតំបន់បន្តមានកំណើនយឺតក្នុងស្ថានភាពប្រឈមពីការប្រែប្រួលនិន្នាការសេដ្ឋកិច្ច រួមមាន បញ្ហាការកើនឡើងចំនួនប្រជាជនវ័យចំណាស់ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធពាណិជ្ជកម្មសកល និងការផ្លាស់ប្ដូរបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។

ប្រជាជនវ័យចំណាស់ បាននិងកំពុងកើនឡើងលឿននៅតាមបណ្ដាប្រទេសក្នុងតំបន់អាស៊ាន+៣ ជាងនៅតំបន់ផ្សេងទៀតនៅលើពិភពលោក។ ចំនួនប្រជាជនក្នុងអាយុធ្វើការសរុបក្នុងតំបន់ត្រូវបានព្យាករថានឹងថយចុះនៅក្នុងរយៈពេល៥ឆ្នាំខាងមុខ ដែលនឹងបង្កឱ្យមានបច្ច័យអវិជ្ជមានចំពោះកំណើនសក្ដានុពលក្នុងតំបន់ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងនិរន្តរភាពនៃហិរញ្ញវត្ថុសាធារណៈ។ ទោះយ៉ាងណាក្ដី ផលប៉ះពាល់ទាំងនេះមិនត្រូវបានកំណត់ជាមុន និងអាចកាត់បន្ថយបាន ជាពិសេសប្រសិនបើប្រជាជនត្រូវបានអនុញ្ញាត និងអាចប្រែទៅជាវ័យចំណាស់ប្រកបដោយផលិតភាព។ នៅពេលពិចារណាពីអាយុកាលរស់នៅប្រកបដោយសុខុមាលភាពក្នុងតំបន់អាស៊ាន+៣ គោលនយោបាយដែលគាំទ្រ និងផ្សព្វផ្សាយឱ្យមានការរស់នៅប្រកបដោយសុខភាពល្អនិងអាយុវែង អាចធ្វើឱ្យមានចំនួនប្រជាជនវិលត្រឡប់ចូលក្នុងកម្លាំងពលកម្មវិញប្រមាណ ២០០ លាននាក់ក្នុងឆ្នាំ២០២៥។

ការបន្តរៀបចំឡើងវិញនូវរចនាសម្ព័ន្ធពាណិជ្ជកម្មសកល អាចមានផលប៉ះពាល់ចំពោះយុទ្ធសាស្ត្រនាំចេញរយៈពេលសាកល្បងក្នុងតំបន់។ ជវភាពភូមិសាស្ត្រនយោបាយ (Geopolitical Dynamics) បាននិងកំពុងបង្កើនការពង្រឹងទំនាក់ទំនងពាណិជ្ជកម្មសកល និងបង្ហាញកាលានុវត្តភាពពាណិជ្ជកម្មថ្មីសម្រាប់ប្រទេសក្នុងតំបន់អាស៊ាន+៣ ដែលអាចពង្រីកនូវឧត្ដមភាពពាណិជ្ជកម្មរបស់ខ្លួនបានយ៉ាងឆាប់រហ័ស។ ជាមួយគ្នានេះ ពាណិជ្ជកម្មក្នុងតំបន់ត្រូវបានផ្ដោតទៅលើប្រទេសដៃគូពាណិជ្ជកម្មមួយចំនួនប៉ុណ្ណោះ ហើយនៅក្នុងបរិបទដែលសេដ្ឋកិច្ចពិភពលោកកំពុងប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ការណ៍នេះអាចធ្វើឱ្យមានសុវត្ថិភាពសេដ្ឋកិច្ចទាប។ ដោយឡែក ការអនុវត្តសេវាពាណិជ្ជកម្មឆ្លងដែន ជាពិសេសសេវាកម្មដឹកជញ្ជូនទំនិញបែបទំនើប និងឌីជីថល នឹងផ្ដល់នូវកាលានុវត្តភាពយ៉ាងសំខាន់សម្រាប់កំណើន និងពិពិធកម្ម។

បច្ចេកវិទ្យានឹងផ្ដល់ជាដំណោះស្រាយជាច្រើន ដែលប្រទេសក្នុងតំបន់អាស៊ាន+៣ អាចប្រើដើម្បីតម្រង់ទិសទៅរកដំណើរអន្តរកាលនៃការប្រែប្រួលប្រជាសាស្ត្រ និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធពាណិជ្ជកម្មសកល។ ការអភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងវិស័យវេជ្ជសាស្ត្រ ស្វ័យប្រវត្តិកម្ម និងផ្លែតហ្វមការងារ និងការសិក្សា មានសារៈសំខាន់សម្រាប់ប្រជាជនវ័យចំណាស់ដែលមានផលិតភាព។ បច្ចេកវិទ្យាផលិតកម្មទំនើប និងឡូជីស្ទីកឆ្លាតវៃ នឹងដើរតួយ៉ាងសំខាន់ក្នុងការធ្វើឱ្យខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់មានភាពបត់បែនខ្ពស់ទៅនឹងហានិភ័យផ្សេងៗ។ យ៉ាងណាមិញ បច្ចេកវិទ្យាក៏ជាអ្នកនាំមុខនៃការផ្លាស់ប្ដូរផងដែរ។ ឧទាហរណ៍៖ ជាពិសេស បញ្ញាសិប្បនិម្មិត (Artificial Interlligence) ឬ GenAI បាននិងកំពុងបង្កើនការព្រួយបារម្ភយ៉ាងខ្លាំងសម្រាប់ទីផ្សារការងារនាពេលអនាគត។ វិធីសាស្ត្រប្រកបដោយភាពជាក់ស្ដែង គុណវុឌ្ឍិ និងមានតុល្យភាពទៅលើលទ្ធភាពរបស់ GenAI នឹងក្លាយជាវិធីសាស្ត្រសមស្របមួយនាពេលបច្ចុប្បន្ន។

ខណៈដែលការអនុវត្តគោលនយោបាយរួមចម្រុះ និងការកំណត់ពេលវេលា អាចនឹងមានភាពខុសគ្នារវាងសេដ្ឋកិច្ចក្នុងតំបន់ គោលនយោបាយក្នុងស្រុកដែលល្អដោយមាន៖ ១) ផ្ដោតលើគុណភាពហេដ្ឋារចនាសម្ព័ន្ធ ២) លើកទឹកចិត្តនវានុវត្តន៍ និង ៣) ជំរុញបរិយាប័ន្ន នឹងអនុញ្ញាតឱ្យប្រទេសនីមួយៗក្នុងតំបន់អាចប្រែក្លាយបញ្ហាប្រឈមទាំងនេះទៅជាកាលានុវត្តភាពកំណើន។

ប្រជាជនវ័យចំណាស់ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធពាណិជ្ជកម្ម និងការផ្លាស់ប្ដូរបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស គឺជាបញ្ហាប្រឈមទូទៅក្នុងរយៈពេលវែង សម្រាប់ប្រទេសទាំងអស់ក្នុងតំបន់។ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាប្រឈមទូទៅទាំងនេះមាន ដូចជាការធ្វើពិពិធកម្ម ការធ្វើឱ្យប្រសើរឡើងនៃហេដ្ឋារចនាសម្ព័ន្ធ ការផ្សព្វផ្សាយបច្ចេកវិទ្យា និងចល័តភាព កម្លាំងពលកម្ម តម្រូវឱ្យមានការពិភាក្សាឱ្យបានច្បាស់លាស់ និងទូលំទូលាយ ក្នុងចំណោមប្រទេស អាស៊ាន+៣ និងដៃគូសេដ្ឋកិច្ចសំខាន់ៗ។ ការពង្រឹងសកម្មភាពរួមគ្នា នឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន+៣ មានភាពរឹងមាំនិងធន់ ទៅនឹងការប្រប្រួលនៃស្ថានភាពសេដ្ឋកិច្ចសកល។

*សំណេរនេះជាការបកប្រែពីភាសាអង់គ្លេសដើមសម្រាប់គោលបំណងផ្ដល់ព័ត៌មានតែប៉ុណ្ណោះ។ ក្នុងករណីមានភាពខុសគ្នា គួរយោងទៅសំណេរភាសាអង់គ្លេស។*

EN
ID
MS
ZH
JA
KM
KO
LO
MY
TH
VI

## អាស៊ាន+៣៖ ជម្រើសគោលនយោបាយសំខាន់ៗសម្រាប់តម្រង់ទិសនាពេលអនាគត

### ការកើនឡើងប្រជាជនវ័យចំណាស់

- សម្របសម្រួលនូវគោលនយោបាយ និងរចនាសម្ព័ន្ធនានាដែលអនុញ្ញាតឱ្យប្រជាជនឈានទៅរកវ័យចំណាស់ប្រកបដោយផលិតភាព
- លើកទឹកចិត្តអ្នកធ្វើការវ័យចំណាស់ (ជាពិសេសស្ត្រី) ឱ្យចូលរួម និងចូលរួមឡើងវិញនៅក្នុងកម្លាំងពលកម្ម
- ប្រើប្រាស់បច្ចេកវិទ្យាដើម្បីបំពេញបន្ថែមលើពលកម្ម ឬចាប់យកការធ្វើស្វ័យប្រវត្តិកម្មខ្ពស់
- ធ្វើកំណែទម្រង់ប្រព័ន្ធសន្តិសុខសង្គម ដើម្បីបញ្ចូលអាយុសង្ឃឹមរស់រវែងជាងមុននិងប្រកបដោយសុខុមាលភាព
- ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីសម្រួលដល់ចល័តភាពកម្លាំងពលកម្ម និងការចែករំលែកចំណេះដឹង

### ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធពាណិជ្ជកម្ម

- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់លើបញ្ហាប្រឈមរួមគ្នា
- ជំរុញកិច្ចសហប្រតិបត្តិការសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងកាត់បន្ថយឧបសគ្គពាណិជ្ជកម្មដែលមានស្រាប់
- លើកកម្ពស់ការប្រកួតប្រជែងកាន់តែខ្ពស់ និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពឧស្សាហកម្ម
- ធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យកាន់តែទូលំទូលាយ ដើម្បីឈានទៅចាប់យកទីផ្សារថ្មីៗ និងស្វែងរកការនាំចេញថ្មីៗ

### ការផ្លាស់ប្តូរបច្ចេកវិទ្យា

បច្ចេកវិទ្យាដើម្បីទទួលបានផលពីការរស់នៅអាយុវែង

បច្ចេកវិទ្យាសម្រាប់ភាពធន់នៃពាណិជ្ជកម្ម

- ជំរុញនវានុវត្តន៍ និងពង្រឹងសមត្ថភាពរបស់អ្នកដឹកនាំបច្ចេកវិទ្យាក្នុងតំបន់អាស៊ាន+៣
- បង្កើនកិច្ចសហការរបស់ភាគីពាក់ព័ន្ធ ដើម្បីលើកទឹកចិត្តការផ្សព្វផ្សាយបច្ចេកវិទ្យានៅក្នុងតំបន់ និងជាមួយប្រទេសនានា
- ផ្តោតអាទិភាពលើហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង ដើម្បីសម្រួលដល់ភាពរួចរាល់ និងការស្រូបយកបច្ចេកវិទ្យា
- កាត់បន្ថយគម្លាតឌីជីថលទាំងក្នុងតំបន់ និងប្រទេសជាសមាជិក និងធ្វើឱ្យបច្ចេកវិទ្យាកាន់តែប្រសើរ

ប្រភព៖ បុគ្គលិក AMRO។

*សំណេរនេះជាការបកប្រែពីភាសាអង់គ្លេសដើមសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ក្នុងករណីមានភាពខុសគ្នា គួរយោងទៅសំណេរភាសាអង់គ្លេស។*